

ក្រសួងកិច្ចការនារី

សេចក្តីសង្ខេបសម្រាប់គោលនយោបាយ ១

# យេនឌ័រ

## ការបញ្ជ្រាបយេនឌ័រ

### បរិបទគោលនយោបាយ ស្ថាប័ន និងភាពជាដៃគូ

### ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា

២០១៤

រូបភាពគំរបមុខ

**លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងមន្ត្រីវ័យក្មេង នៃក្រសួងកិច្ចការនារី

## ជំពូកទី ១

# ការបញ្ជ្រាបយេនឌ័រ

## បរិបទគោលនយោបាយ ស្ថាប័ន និងភាពជាដៃគូ

### បរិបទគោលនយោបាយ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានបញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាពចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (មាត្រា៣៥) មានសិទ្ធិជ្រើសរើសមុខរបរសមស្រប ទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងគ្រប់ប្រភេទលើស្ត្រី (មាត្រា៤៥)។

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី៣ នៅតែបន្តប្តេជ្ញាក្នុងការលើកស្ទួយស្ថានភាពស្ត្រី ដែលជាឆ្អឹងខ្នងនៃសង្គម និងសេដ្ឋកិច្ចជាតិ តាមរយៈការអនុវត្តន៍ការលើកកម្ពស់សមភាពយេនឌ័រ។

គោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា នៅក្នុងគោលដៅទី៣ គឺជាក្របខណ្ឌដាក់លាក់ដែលបង្ហាញអំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការសម្រេចបាននូវសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ជាពិសេសលើការអប់រំ ការអភិវឌ្ឍន៍សេដ្ឋកិច្ចសេវាសាធារណៈ និងការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ គឺជាផែនការដាក់លាក់របស់ជាតិដែលបានបង្ហាញថា ការបញ្ជ្រាបយេនឌ័រជាបញ្ហាអន្តរវិស័យ ក្នុងគោលនយោបាយកម្មវិធី និងវិស័យនានា និងបន្តបង្កើនភាពអង់អាចដល់ស្ត្រីក្នុងវិស័យអប់រំ សេដ្ឋកិច្ចការពារផ្លូវច្បាប់ សុខភាព មេរោគអេដស៍ អាហារូបត្ថម្ភ វិស័យសាធារណៈ និងនយោបាយ។



▲ សមធម៌យេនឌ័រ គឺជាគន្លឹះដ៏សំខាន់នៃការអភិវឌ្ឍន៍ជាតិ ។

## របកគំហើញ

### ច្បាប់ និងគោលនយោបាយជាតិដែលបានតាក់តែងឡើងសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ៖

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដំណាក់កាលទី៣ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា បានទទួលស្គាល់ថា សមភាពយេនឌ័រជាគន្លឹះមួយក្នុងការអភិវឌ្ឍន៍ជាតិ និងធនធានមនុស្ស ។ រាជរដ្ឋាភិបាលបានបញ្ជាក់អំពីភាពចាំបាច់ក្នុងការកែលម្អ និងលើកស្ទួយស្ថានភាពស្ត្រី ដែលជាឆ្អឹងខ្នងនៃសង្គម និងសេដ្ឋកិច្ចជាតិ ។

ផែនការយុទ្ធសាស្ត្រនារីរតនៈ ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណក្នុងការលើកកម្ពស់ស្ថានភាពស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច អប់រំ ការផ្លាស់ប្តូរឥរិយាបថ ពង្រឹងភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ លុបបំបាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ

ព្រមទាំងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ កម្មវិធី និងវិស័យនានារបស់ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល។

ច្បាប់ការពារសិទ្ធិស្ត្រីដែលបានអនុម័ត រួមមាន៖ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ (ឆ្នាំ១៩៩៧) ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ (ឆ្នាំ២០១៣) ច្បាប់ស្តីពីការងារ (ឆ្នាំ១៩៩៧) ច្បាប់ភូមិបាល (ឆ្នាំ២០០១) ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (ឆ្នាំ២០០៥) ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ (ឆ្នាំ២០០៨) ក្រមរដ្ឋប្បវេណី(ឆ្នាំ២០០៧) ក្រមនីតិវិធីរដ្ឋប្បវេណី (ឆ្នាំ២០០៦) ក្រមព្រហ្មទណ្ឌ (ឆ្នាំ២០០៩) ក្រមនីតិវិធីព្រហ្មទណ្ឌ(ឆ្នាំ២០០៧) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ឆ្នាំ២០០៨) ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ឆ្នាំ២០០៨) និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ (ឆ្នាំ២០០៦)។

នៅក្នុងគោលដៅទាំង៦ នៃគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍន៍យុវជនកម្ពុជា (ឆ្នាំ២០១១) រាជរដ្ឋាភិបាលបានកំណត់គោលដៅមួយ ក្នុងការលើកកម្ពស់យេនឌ័រប្រកបដោយសមធម៌ និងសមភាពដល់យុវជនទាំងពីរភេទ ជាពិសេសផ្តល់ឱកាស និងសិទ្ធិអំណាចដល់ស្ត្រី ។

នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដែលរួមមានវិធានការសំខាន់ៗជាច្រើនក្នុងនោះមានចំណុចដែលពាក់ព័ន្ធនឹង «គ្មានអំពើហិង្សាក្នុងគ្រួសារ» និង «គ្មានការជួញដូរស្ត្រីនិងកុមារ»។

ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ បានចាប់ផ្តើមនៅចុងឆ្នាំ២០១២ ខណៈដែលក្រសួងកិច្ចការនារីបានចូលរួមយ៉ាងសកម្មក្នុងការដាក់បញ្ចូលសូចនាករទាក់ទងនឹងសមភាពយេនឌ័រ ក៏ដូចជាការផ្តល់យោបល់ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់វិស័យដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះរបស់ស្ត្រី ជាពិសេសស្ត្រីពិការ និងស្ត្រីជនជាតិដើមភាគតិច។

សូចនាករត្រួតពិនិត្យរួមគ្នា ត្រូវបានរៀបចំ និងតាមដានត្រួតពិនិត្យដោយក្រុមការងារបច្ចេកទេស ចម្រុះចំនួន១៩ ជារៀងរាល់១៨ខែម្តង ក៏ប៉ុន្តែចាប់ពីឆ្នាំ២០១៤មក ក្រុមការងារ

បានកំណត់រយៈពេល៥ឆ្នាំសម្រាប់ការតាមដានលើភាពរីកចម្រើន នៃសូចនាករត្រួតពិនិត្យរួមគ្នាដោយមានការឯកភាពពីវេទិកាកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍កម្ពុជា ។ សូចនាករទាក់ទងនឹងសមភាពយេនឌ័របានកំណត់សម្រាប់វាស់វែង និងពង្រឹងគុណភាពនៃការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី តាមរយៈការផ្សព្វផ្សាយរបាយការណ៍នៃការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា និងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ នារីរតនៈទី៤ ក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលកម្ពុជា ដែលនឹងបញ្ចប់ការរៀបចំគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រក្នុងឆ្នាំ២០១៥ខាងមុខនេះ ព្រមទាំងការរៀបចំអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី សម្រាប់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ។

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា បានពង្រីកពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សកល ដោយបញ្ចូលសូចនាករទាក់ទងនឹងបញ្ហាយេនឌ័រ និងគោលដៅបន្ថែមមួយចំនួនទៀត។ គោលដៅទីបី នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ផ្តោតលើការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី  តាមរយៈការកាត់បន្ថយគម្លាតយេនឌ័រក្នុងវិស័យអប់រំ ការបង្កើនការចូលរួមរបស់ស្ត្រីក្នុងជួររាជរដ្ឋាភិបាលនិងជានាប្រាក់ឈ្នួលស្មើគ្នារវាងបុរស និងស្ត្រី។ ព្រះរាជាណាចក្រកម្ពុជាគឺជាប្រទេសដំបូងគេបង្អស់ដែលបានដាក់បញ្ចូលសូចនាករស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីនៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ខ្លួន។

នៅឆ្នាំ២០០៩ រាជរដ្ឋាភិបាលបានអនុម័ត និងដាក់ឱ្យអនុវត្តនូវផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ។បច្ចុប្បន្ននេះ សេចក្តីព្រាងផែនការសកម្មភាពជាតិទីពីរ កំពុងដំណើរការក្នុងការពិភាក្សា និងអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា ។

ក្របខ័ណ្ឌពន្លឿនគោលដៅសហស្សវត្សរ៍ ឆ្នាំ២០១២-២០១៥ ក្នុងគោលដៅពន្លឿនសមិទ្ធផលគោលដៅទី៣ ដោយផ្តោតលើការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី បានបង្កើតឡើងដើម្បីកៀគរស្ថាប័នរាជរដ្ឋាភិបាល វិស័យឯកជន ក៏ដូចជាដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។ ក្របខ័ណ្ឌនេះចូលរួមក្នុងការសម្រេចបាននូវគោលដៅជាក់លាក់បីៈ

១. ការពង្រឹងជំនាញវិជ្ជាជីវៈសម្រាប់ស្ត្រីដោយផ្អែកលើតម្រូវការទីផ្សារ

២. បង្កើតសហគ្រាសខ្នាតតូចនិងមធ្យម

៣. កែលម្អជីវភាពរស់នៅតាមតំបន់ជនបទ។

បច្ចុប្បន្នក្រសួងកិច្ចការនារីកំពុងរៀបចំកម្មវិធីស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីរយៈពេលវែងដែលជាមូលដ្ឋានសម្រាប់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីសម្រាប់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។

## បរិបទសកល

ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ និងផ្តល់សច្ចាប័ន ក្លាយទៅជារដ្ឋភាគី នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ ពិធីសារតាមជម្រើសនៃអនុសញ្ញាបាន ចុះហត្ថលេខានៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០១ និងផ្តល់សច្ចាប័ននៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០។ អនុសញ្ញានេះរួមបញ្ចូលនូវវិធានការលើកកម្ពស់ស្ថានភាពស្ត្រី និងសិទ្ធិស្ត្រីតាមរយៈដំណើរការច្បាប់ និងការអនុវត្តន៍របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន រដ្ឋភាគីកម្ពុជាបានផ្ញើរបាយការណ៍ជូនគណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកចំនួនពីរលើកគឺនៅឆ្នាំ២០០៣ របាយការណ៍ផ្តួបលើកដំបូង លើកទី២ និងលើកទី៣ ហើយបានទទួលមកវិញនូវយោបល់សន្និដ្ឋានចំនួន៤២ចំណុចនៅឆ្នាំ២០០៦។ នៅ ឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានផ្ញើរបាយការណ៍ផ្តួបលើកទី៤ និងលើកទី៥ ហើយបានទទួលមកវិញនូវសេចក្តីសង្កេតសន្និដ្ឋានចំនួន៥២ចំណុចនៅឆ្នាំ២០១៣។ នៅក្នុងផែនការនារីរតនៈទី៤របស់ក្រសួងកិច្ចការនារីក៏បានបញ្ចូលនូវសេចក្តីសន្និដ្ឋានទាំងនោះផងដែរ។

រាជរដ្ឋាភិបាលកម្ពុជា បានចូលរួមនៅក្នុងសន្និសីទស្តីពីស្ត្រីពិភពលោកលើកទី៤នៅទីក្រុងប៉េកាំង ដែលបានអនុម័តនូវផែនការសកម្មភាពទីក្រុងប៉េកាំង និងបានរៀបចំរបាយការណ៍រីកចម្រើនចាប់ពីឆ្នាំ១៩៩៥មក។ ផ្អែកតាមតួនាទី និងមុខងារនៃយន្តការជាតិសម្រាប់សមភាពយេនឌ័រ និងការអភិវឌ្ឍន៍ស្ត្រី ផែនការសកម្មភាពដើម្បីលើកកម្ពស់ស្ថានភាពស្ត្រីនៅទីក្រុងប៉េកាំងបានកំណត់កត្តាសំខាន់ៗចំនួនបួនដើម្បីទទួលបានជោគជ័យក្នុងការប្រព្រឹត្តទៅនៃយន្តការជាតិ ដែលមានដូចខាងក្រោម៖

- មានការយកចិត្តទុកដាក់និងគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា។
- ប្រព័ន្ធដែលធ្វើឱ្យមានការគាំទ្រយ៉ាងសកម្ម និងការចូលរួមយ៉ាងទូលំទូលាយក្នុងការលើកកម្ពស់ស្ថានភាពស្ត្រីរួមទាំងស្ថាប័ននីតិប្បញ្ញត្តិ គ្រឹះស្ថានសិក្សា និងស្ថាប័នសិក្សា



▲ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ទទួលស្គាល់ថាស្ត្រីគឺជាឆ្អឹងខ្នងនៃសង្គម និងសេដ្ឋកិច្ច

ស្រាវជ្រាវ សមាគមអាជីព សហជីពកម្មករ ក្រុមសហគមន៍មូលដ្ឋាន អង្គការស្ត្រីមិនមែនរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ ក្រុមសាសនា អង្គការយុវជន និងវិស័យឯកជន។

- ការបែងចែកធនធានហិរញ្ញវត្ថុនិងធនធានមនុស្សឱ្យបានគ្រប់គ្រាន់។
- បង្កឱកាសឱ្យស្ត្រីចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចសាធារណៈនៅក្នុងរាជរដ្ឋាភិបាល។

របៀបវារៈសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពបន្ទាប់ពីឆ្នាំ២០១៥៖ គោលដៅកម្រិតសកលបានបង្កើតឡើងរួមបញ្ចូលទាំង«គោលដៅដោយឡែកដើម្បីសម្រេចបាននូវសមភាពយេនឌ័រ សិទ្ធិស្ត្រី និងការបង្កើនភាពអង់អាចដល់ស្ត្រី» (សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិសម្រាប់ស្ត្រី ឆ្នាំ២០១៤) បានកំណត់គោលដៅសំខាន់ៗចំនួនបី៖ សេរីភាពដែលរួចផុតពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី សមភាពយេនឌ័រដោយផ្អែកលើសមត្ថភាពនិងធនធាន រួមទាំងឱកាសក្នុងការទទួលបានការអប់រំ

ការពិនិត្យថែទាំសុខភាព ការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងសមភាពយេនឌ័រក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈនិងឯកជន។ ក្រសួងកិច្ចការនារីបានកំណត់ផ្នែកនេះសម្រាប់ការពិចារណាជាកម្មវិធីអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤។

## គោលនយោបាយយេនឌ័រ និងផែនការជាតិជាក់លាក់

**ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា៖** ក្រសួងកិច្ចការនារីបានធ្វើការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា ជារៀងរាល់៥ឆ្នាំម្តង (ឆ្នាំ២០០៤ ២០០៨ និងឆ្នាំ២០១៤) ដែលផ្តល់នូវទិដ្ឋភាពដ៏ទូលំទូលាយអំពីយេនឌ័រលើគ្រប់វិស័យ។ ឯកសារនេះបានរៀបចំឡើងក្នុងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការរវាងក្រសួងកិច្ចការនារី ក្រសួង ស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយគ្រប់ភាគីពាក់ព័ន្ធ។ ឯកសារនេះគឺជាមូលដ្ឋានសម្រាប់ការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីតាមវិស័យរបស់ក្រសួង ស្ថាប័ន និងជាមគ្គុទេសក៍ក្នុងការតាក់តែងគោលនយោបាយ ផែនការ និងកម្មវិធីនានាដើម្បីសមភាពយេនឌ័រ និងកិច្ចអភិវឌ្ឍន៍។

**ផែនការយុទ្ធសាស្ត្រនារីរតនៈ និងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ៖** ក្រសួងកិច្ចការនារីបានអនុវត្តផែនការយុទ្ធសាស្ត្រ៥ឆ្នាំចំនួនបីដំណាក់កាលរួចមកហើយចាប់ពីឆ្នាំ១៩៩៩-២០១៣(នារីរតនៈទី១ ទី២និងទី៣) ដើម្បីរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រីកម្ពុជា។ រាល់ផែនការយុទ្ធសាស្ត្រនារីរតនៈ បានកំណត់ថា «តួនាទីរបស់ក្រសួងកិច្ចការនារីគឺ លើកកម្ពស់ការបញ្ជ្រាបយេនឌ័រនៅក្នុងស្ថាប័នរាជរដ្ឋាភិបាល» ដែលចាប់ផ្តើមពីនារីរតនៈទី១ (ឆ្នាំ១៩៩៩)ដែលក្នុងនោះមានការបញ្ជាក់យ៉ាងច្បាស់ថា *«នៅក្នុងអាណត្តិថ្មីរបស់ខ្លួនក្រសួងកិច្ចការនារីនឹងដើរតួនាទីជាកាតាលីករ ដើម្បីលើកទឹកចិត្តក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការដាក់បញ្ចូលកង្វល់ទាំងឡាយទាក់ទងនឹងសមភាពយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីរបស់ខ្លួន»*។

ក្រសួងកិច្ចការនារីកំពុងរៀបចំបញ្ចប់*ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤* ដែលនឹងផ្លាស់ប្តូរពីការអនុវត្តន៍ផ្តោតលើគម្រោងតូចៗ ទៅជាការអនុវត្តន៍តាមបែបអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងពីការអនុវត្តន៍ផ្តោតលើការផ្តល់សេវាទៅជាការលើកកម្ពស់គណនេយ្យភាពសង្គមសម្រាប់ស្ត្រី និងការផ្តល់សេវាប្រឹក្សាផ្នែកគោលនយោបាយជាយុទ្ធសាស្ត្រ ក្នុងការបញ្ជ្រាប

យេនឌ័រទៅក្នុងក្រសួង ស្ថាប័ន។ *ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤* បានរៀបចំឡើងដើម្បីឆ្លុះបញ្ចាំងពីការកែសម្រួលមុខងាររបស់ក្រសួងកិច្ចការនារីដោយផ្តោតលើការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ការបញ្ជ្រាបយេនឌ័រទៅក្នុងក្រសួង ស្ថាប័នពាក់ព័ន្ធដែលដឹកនាំ និងសម្របសម្រួលដោយក្រសួងកិច្ចការនារី តាមរយៈការផ្តល់សេវាប្រឹក្សា គាំទ្របច្ចេកទេស ការស្វែងរកការគាំទ្រមតិ និងការត្រួតពិនិត្យ។ ផែនការយុទ្ធសាស្ត្រនេះតម្រូវឱ្យក្រសួងកិច្ចការនារីបង្កើនការយកចិត្តទុកដាក់លើការបញ្ជ្រាបយេនឌ័រទៅក្នុងក្រសួង ស្ថាប័នពាក់ព័ន្ធ និងផ្តោតលើការវិភាគ ការរៀបចំគោលនយោបាយ ច្រើនជាងការអនុវត្តន៍គម្រោង និងការផ្តល់សេវានៅថ្នាក់មូលដ្ឋាន តាមរយៈការត្រួតពិនិត្យ ការរៀបចំផែនការ និងថវិកា ការអនុវត្តន៍គម្រោង និងរបាយការណ៍។

លើសពីនេះទៀត ក្រសួងកិច្ចការនារីកំពុងដំណើរការរៀបចំគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ដែលនឹងបញ្ចប់នៅឆ្នាំ២០១៥ ហើយនឹងដាក់ចេញនូវគោលដៅ និងគោលបំណងរួមសម្រាប់ការបញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងកម្រិតគោលនយោបាយ។

## យន្តការស្ថាប័នសម្រាប់ការបញ្ជ្រាបយេនឌ័រ

### *ថ្នាក់ជាតិ*

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការនារី នៅឆ្នាំ១៩៩៣ និងបានដំឡើងជាក្រសួងកិច្ចការនារី និងអតីតយុទ្ធជន នៅឆ្នាំ១៩៩៨ ហើយបានក្លាយមកជាក្រសួងកិច្ចការនារីនៅឆ្នាំ២០០៣។ ក្រសួងកិច្ចការនារីមានតួនាទី និងភារៈកិច្ចជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ស្ថានភាពស្ត្រី និងការពារសិទ្ធិរបស់ស្ត្រី និងគ្រួសារតាមរយៈការអនុវត្តន៍ផែនការយុទ្ធសាស្ត្រនារីរតនៈ។ ក្រសួងដើរតួនាទីក្នុងការលើកកម្ពស់សមភាពយេនឌ័រ ក្នុងច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីជាតិនានា។ ក្រសួងកិច្ចការនារីមានអគ្គនាយកដ្ឋានចំនួន៣ និងមាននាយកដ្ឋានចំនួន១១ ព្រមទាំងមានមន្ទីរកិច្ចការនារី រាជធានី ខេត្ត និងមានការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌទូទាំងប្រទេស និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីក្នុងខេត្តចំនួន១៣ ។

ក្រៅពីកម្មវិធីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី កម្មវិធីអប់រំស្ត្រីនិងក្មេងស្រី កម្មវិធីលើកកម្ពស់សុខភាពស្ត្រី និងក្មេងស្រី និងកិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី

ព្រមទាំងការលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យសាធារណៈ និងនយោបាយ ក្រសួងបាននិងកំពុងជំរុញការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ ផែនការ និងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជា កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កម្មវិធីនិងការបញ្ជ្រាបយេនឌ័រតាមវិស័យរួមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីវិនិយោគសាធារណៈ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ល។ ក្រសួងកិច្ចការនារីមានផែនការយុទ្ធសាស្ត្រ «នារីរតនៈ» រយៈពេល៥ឆ្នាំ និងបច្ចុប្បន្នកំពុងតែដំណើរការរៀបចំផែនការនារីរតនៈទី៤ (២០១៤-២០១៨) និងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ។

**ក្រសួងកិច្ចការនារីដឹកនាំនិងសម្របសម្រួលគណៈកម្មាធិការមួយចំនួនសម្រាប់ដោះស្រាយបញ្ហាទាក់ទងនឹងយេនឌ័រ ដូចខាងក្រោម៖**

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (ក.ជ.ក.ស) ដែលបានបង្កើតឡើងនៅឆ្នាំ២០០១ គឺជាយន្តការជាតិអន្តរក្រសួង ស្ថាប័ន ដែលមានសមាជិកថ្នាក់រដ្ឋលេខាធិការមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។ ក.ជ.ក.ស មានភារកិច្ចជួយរាជរដ្ឋាភិបាលក្នុងការសម្របសម្រួលតាមដាន និងវាយតម្លៃការអនុវត្តន៍គោលនយោបាយជាតិ ច្បាប់ បទប្បញ្ញត្តិនានាដែលទាក់ទងនឹងការលើកកម្ពស់ឋានៈ តួនាទីស្ត្រី និងសុខុមាលភាពរបស់ស្ត្រីកម្ពុជា[1]។ ក.ជ.ក.ស មានតួនាទីតាមដាន និងវាយតម្លៃនូវការអនុវត្តន៍អនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិនារី ដើម្បីផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាល ក្នុងគោលដៅលើកកម្ពស់ស្ថានភាពស្ត្រីឱ្យកាន់តែប្រសើរឡើង និងរៀបចំរបាយការណ៍ជាតិលើការអនុវត្តន៍អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារី។ ក.ជ.ក.សដឹកនាំដោយសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាព្រះប្រធានកិត្តិយស សម្តេចនាយករដ្ឋមន្ត្រី ជាអនុប្រធានកិត្តិយស រដ្ឋមន្ត្រីក្រសួងកិច្ចការនារីជាប្រធានប្រតិបត្តិ និងតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ ជាសមាជិក សមាជិកា។ ក.ជ.ក.ស មានផែនការយុទ្ធសាស្ត្រប្រាំឆ្នាំ២០១០-២០១៤របស់ខ្លួនដែលមិនចំណុះផែនការយុទ្ធសាស្ត្រនារីរតនៈ។

---

[1] ព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នស/រកត០២០១/០៣៦ ឆ្នាំ២០០១



▲ នារីរតនៈទី៤ គូសបញ្ជាក់អំពីការអភិវឌ្ឍន៍សមត្ថភាពនៃការបញ្ជ្រាបយេនឌ័រលើគ្រប់វិស័យ

- គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងមានសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។ គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ បានបង្កើតឡើងក្នុងគោលបំណងថែរក្សាការពារវប្បធម៌ជាតិ ធានាដល់ការគោរពសីលធម៌សង្គម និងសុភមង្គលនៅក្នុងគ្រួសារដោយលើកកម្ពស់ស្ថានភាព តួនាទី និងសុខុមាលភាពស្ត្រីខ្មែរ។
- គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី បានបង្កើតឡើងនៅក្នុងខែតុលាឆ្នាំ២០១២ ក្នុងគោលបំណងសម្របសម្រួល និងដឹកនាំការបង្កើតនិងអនុវត្តន៍ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីឆ្ពោះទៅរកសមភាពយេនឌ័រ ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងមានសមាជិកចំនួន១២រូបជារដ្ឋលេខាធិការ និងជាអគ្គនាយក ព្រមទាំងមានលេខាធិការដ្ឋានមួយដើម្បីគាំទ្រដល់

ការងាររបស់ខ្លួន។ តួនាទីចម្បង និងការទទួលខុសត្រូវរបស់គណៈកម្មាធិការនេះមាន ដូចតទៅ៖ រៀបចំអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី (PBA) សម្របសម្រួលកិច្ចសហការ ការកៀរគរធនធាន និងការអភិវឌ្ឍន៍សមត្ថភាព។

- គណៈកម្មាធិការយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ដែលបានបង្កើតឡើងនៅក្នុងខែកញ្ញាឆ្នាំ២០១១ដឹកនាំដោយរដ្ឋលេខាធិការមួយរូប និងមានសមាជិកមកពីអគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធមួយចំនួន។ គណៈកម្មាធិការនេះបានបង្កើតឡើងក្នុងគោលបំណង៖

១. សម្របសម្រួល ចែករំលែកព័ត៌មានបញ្ហាបយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ជាមួយស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ មន្ទីរកិច្ចការនារី រាជធានី ខេត្ត និងការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ

២. សិក្សាស្រាវជ្រាវអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយផ្សេងៗចំពោះមនុស្ស ជាពិសេស ផលប៉ះពាល់មកលើស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះ

៣. អភិវឌ្ឍសមត្ថភាពក្រុមការងារ មន្ត្រីក្រសួងកិច្ចការនារី និងក្រសួងស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីយល់ដឹងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយ ការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ។

## *ថ្នាក់ក្រោមជាតិ*

**មន្ទីរកិច្ចការនារី**រាជធានី ខេត្ត និងការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ គឺជារចនាសម្ព័ន្ធ ថ្នាក់ក្រោមជាតិ និងអង្គភាពចំណុះរបស់ក្រសួងកិច្ចការនារី។ អង្គភាពទាំងនោះធ្វើការជាមួយមន្ទីរ ការិយាល័យ និងអង្គភាពពាក់ព័ន្ធផ្សេងទៀតដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានតួនាទីគាំទ្រ សម្របសម្រួល និងធ្វើការសិក្សាស្រាវជ្រាវដើម្បីផ្តល់ព័ត៌មាន ព្រមទាំងគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើបញ្ហាពាក់ព័ន្ធស្ត្រី កុមារ និងយុវវ័យនៅថ្នាក់មូលដ្ឋានរបស់ខ្លួន។

**គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ** ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ក.ស.ក) ជាយន្តការថ្នាក់ក្រោមជាតិដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងកុមារ ក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ គ.ក.ស.ក មានមុខងារ និងភារកិច្ចក្នុងការផ្តល់យោបល់ និងអនុសាសន៍ជូនក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការផ្សេងទៀតលើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រ និងបញ្ហារបស់ស្ត្រី យុវវ័យ និងកុមារ។ បច្ចុប្បន្ន ក្នុងក្របខ័ណ្ឌគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ក្រសួងកិច្ចការនារី មានភារកិច្ចគាំទ្រដល់មន្ទីរកិច្ចការនារី រាជធានី ខេត្ត និងការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ ក្នុងការបំពេញភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការនេះ។ ចំណែកឯក្រសួងមហាផ្ទៃ គាំទ្រលើការអភិវឌ្ឍន៍សមត្ថភាព និងការបំពេញភារកិច្ចរបស់គណៈកម្មាធិការនេះជារួម។ គ.ក.ស.កនីមួយៗដឹកនាំដោយប្រធានមួយរូបដែលជាសមាជិកាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមានអនុប្រធាន ដែលជាអភិបាលរងនៃគណៈអភិបាល រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុប្រធានបីរូបទៀតមកពីសមាជិកក្រុមប្រឹក្សារាជាធានី ខេត្ត ក្រុង ស្រុកខណ្ឌ តំណាងមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតិសម្បទា និងតំណាងមន្ទីរកិច្ចការនារី ។

**គណៈកម្មាធិការការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់** (គ.ក.ន.ក) ជាគណៈកម្មាធិការទទួលបន្ទុកលើបញ្ហាស្ត្រី និងកុមារ ដែលទទួលខុសត្រូវចំពោះបញ្ហាដែលទាក់ទងនឹងកិច្ចអភិវឌ្ឍសង្គម ដូចជាសុខភាពមាតា មតេយ្យសិក្សាសហគមន៍ អនាម័យទឹកស្អាត សមភាពយេនឌ័រនិងកិច្ចការពារកុមារ។ សមាសភាពនៃ គ.ក.ន.ក រួមមាន៖ មេឃុំ ឬចៅសង្កាត់ ជាប្រធាន ជំទប់ទី២ឬចៅសង្កាត់រងទី២ ជាអនុប្រធាន និងអ្នកទទួលបន្ទុកកិច្ចនារី និងកុមារឃុំ សង្កាត់ជាសមាជិកអចិន្ត្រៃយ៍ រួមទាំងតំណាងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ តំណាងសាលារៀន តំណាងមណ្ឌលសុខភាព និងថ្នាក់ដឹកនាំភូមិជាសមាជិក។

**អ្នកទទួលបន្ទុកកិច្ចនារី និងកុមារឃុំ សង្កាត់** (អ.ក.ន.ក) ជាប្រតិបត្តិករ និងជាតំណាង កិច្ចការស្ត្រីនិងកុមារនៅថ្នាក់ឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់តែងតាំងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ម្នាក់ជានារី ឱ្យទទួលបន្ទុកកិច្ចការនារី និងកុមារ។ ក្នុងករណីគ្មាននារីជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវជ្រើសតាំងនារីមួយរូបធ្វើជាជំនួយការទទួលបន្ទុកកិច្ចការនារី និងកុមារ។

# គ.ជ.អ.ប និងក្រសួង ស្ថាប័ននានា

ក្រសួងកិច្ចការនារី

មន្ទីរកិច្ចការនារី រាជធានី ខេត្ត

គ.ក.ស.ក ថ្នាក់រាជធានី ខេត្ត៖
- សមាជិកក្រុមប្រឹក្សារាជធានី ខេត្តជាស្ត្រី ជាប្រធាន
- អភិបាលនៃគណៈអភិបាលរង រាជធានី ខេត្ត ជាស្ត្រី ជាអនុប្រធាន
- មន្ទីរកិច្ចការនារីរាជធានី ខេត្ត អនុប្រធានអចិន្ត្រៃយ៍
- មន្ទីរ អង្គភាពនានា ជាសមាជិក

- ក្រុមប្រឹក្សា រាជធានី ខេត្ត
- អភិបាលនៃគណៈអភិបាល រាជធានី ខេត្ត
- គណៈកម្មាធិការនានា

ការិយាល័យ កិច្ចការនារី ក្រុង ស្រុក ខណ្ឌ

គ.ក.ស.ក ថ្នាក់ក្រុង ស្រុក ខណ្ឌ៖
- សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌជាស្ត្រី ជាប្រធាន
- អភិបាលនៃគណៈអភិបាលរងក្រុង ស្រុក ខណ្ឌ ជាស្ត្រី ជាអនុប្រធាន
- កិច្ចការនារីក្រុង ស្រុក ខណ្ឌ អនុប្រធានអចិន្ត្រៃយ៍
- មន្ទីរ អង្គភាពនានា ជាសមាជិក

- ក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ
- អភិបាលនៃគណៈអភិបាល ក្រុងស្រុក ខណ្ឌ
- គណៈកម្មាធិការនានា

អ្នកទទួលបន្ទុក កិច្ចការនារី និង កុមារ ឃុំ សង្កាត់

គ.ក.ន.ក ថ្នាក់ឃុំ សង្កាត់៖
- មេឃុំ ឬចៅសង្កាត់ ជាប្រធាន
- ជំទប់ទី២ឬចៅសង្កាត់រងទី២ ជាអនុប្រធាន
- អ្នកទទួលបន្ទុកកិច្ចនារី និងកុមារឃុំ សង្កាត់ជាសមាជិកអចិន្ត្រៃយ៍
- នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ សាលារៀន តំណាងមណ្ឌលសុខភាព និងថ្នាក់ដឹកនាំភូមិជាសមាជិក

- ក្រុមប្រឹក្សា ឃុំ សង្កាត់
- មេឃុំ ចៅសង្កាត់
- គណៈកម្មាធិការនានា

→ គាំទ្រដោយប្រយោល　　→ គាំទ្រដោយផ្ទាល់



▲ រាជរដ្ឋាភិបាលផ្សព្វផ្សាយសមភាពយេនឌ័រដល់យុវជន

**មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី** (ម.អ.ស) បានបង្កើតឡើងនៅក្នុងខេត្តចំនួន ១៣ដើម្បីគាំទ្រដល់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅមូលដ្ឋាន។ ម.អ.ស ជាមជ្ឈមណ្ឌលសម្របសម្រួល និងផ្ដល់សេវាអភិវឌ្ឍសហគ្រាស ជំនាញបច្ចេកទេស គ្រប់គ្រងកម្មវិធីអក្ខរកម្ម និងជំនាញបំណិនជីវិតដល់ស្ត្រី។ បច្ចុប្បន្ន ម.អ.ស ផ្ដល់វគ្គបណ្ដុះបណ្ដាលជំនាញបែបប្រពៃណីដូចជាកាត់ដេរ តម្បាញ អ៊ុតសក់ និងការកែច្នៃម្ហូបអាហារ ជាដើម។ ម.អ.ស មួយចំនួនមានដំណើរការយ៉ាងសកម្ម និងមួយចំនួនទៀតពុំសូវមានដំណើរការ។ បច្ចុប្បន្នក្រសួងកិច្ចការនារីកំពុងសិក្សា និងស្វែងរកជម្រើសនានា ដើម្បីធ្វើឱ្យប្រសើរឡើងនូវដំណើរការនៃ ម.អ.ស ដូចជាកម្មវិធីភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ជាដើម។

## យន្តការបញ្ជ្រាបយេនឌ័រក្នុងក្រសួង ស្ថាប័ន និងភាពជាដៃគូ

ក្រសួងកិច្ចការនារីលើកទឹកចិត្តឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យរបស់ខ្លួន។ ក្នុងក្របខណ្ឌការងារនៃគណៈកម្មាធិការ

ពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្រុមការងារបច្ចេកទេសចំនួន១៩ បានបង្កើតឡើងសម្រាប់វិស័យសំខាន់ៗ និងក្រុមការងារដែលមានលក្ខណៈជាអន្តរវិស័យ រួមមានក្រុមការងារបច្ចេកទេសយេនឌ័រ ភាពជាដៃគូ និងសុខដុមនីយកម្ម ការរៀបចំ ផែនការ និងកាត់បន្ថយភាពក្រីក្រ និងវិមជ្ឈការនិងវិសហមជ្ឈការ ជាដើម។ ការបង្កើតក្រុមការងារបច្ចេកទេសទាំងអស់នេះគឺជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ចំពោះសេចក្តីប្រកាសទីក្រុងប៉ារីស និងដើម្បីអភិវឌ្ឍផែនការសកម្មភាពសុខដុមនីយកម្មផ្អែកតាមលទ្ធផល ដោយមានគោលដៅ ជារួម គឺការលើកកម្ពស់ប្រសិទ្ធភាពជំនួយ និងដើម្បីពង្រឹងភាពជាម្ចាស់នៃរាជរដ្ឋាភិបាល និងភាពជាអ្នកដឹកនាំរបៀបវារៈនៃការអភិវឌ្ឍន៍។ ក្រុមការងារបច្ចេកទេសយេនឌ័រ បានបង្កើតក្រុមការងារបញ្ជ្រាបយេនឌ័រ តាមក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យរបស់ខ្លួន។

## *ក្រុមការងារបច្ចេកទេសយេនឌ័រ*

ក្រុមការងារបច្ចេកទេសយេនឌ័រ បានបង្កើតឡើងនៅឆ្នាំ២០០៤ ដែលដឹកនាំដោយក្រសួងកិច្ចការនារី និងមានកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន ជាសហអ្នកសម្របសម្រួល និងមានការចូលរួមពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធចំនួន៣១ ដៃគូអភិវឌ្ឍន៍ចំនួន១៤ ព្រមទាំងអង្គការសង្គមស៊ីវិលចំនួន១៥ ជាសមាជិក។ ចាប់តាំងពីបានបង្កើតឡើងមក ក្រុមការងារបច្ចេកទេសយេនឌ័រ បានផ្តល់ជាវេទិកាសម្រាប់ការពិភាក្សានិងជាតុចូលទៅក្នុងការបង្កើតគោលនយោបាយយុទ្ធសាស្ត្រ និងច្បាប់ដែលទាក់ទងនឹងបញ្ហាយេនឌ័រ។

ដើម្បីធ្វើឱ្យមានលទ្ធផលល្អប្រសើរឡើង ក្រុមការងារបច្ចេកទេសយេនឌ័របានបង្កើតក្រុមតូច ដើម្បីសម្របសម្រួលការអនុវត្តន៍វិស័យសំខាន់ចំនួនពីររបស់ក្រសួងកិច្ចការនារី គឺការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងក្របខ័ណ្ឌអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី។

- ក្រុមការងារតូចស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ស្ថិតនៅក្រោមក្រុមការងារបច្ចេកទេសយេនឌ័រ ដែលមានគោលបំណងស្វែងរកការគាំទ្រ និងសម្របសម្រួលការបញ្ជ្រាបយេនឌ័រ ដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រី តាមរយៈការរៀបចំ និងអនុវត្តន៍ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ។ ក្រុមការងារនេះមានតួនាទីសម្របសម្រួលក្នុងការរៀបចំ និងអនុវត្តន៍ផែនការសកម្មភាព

ជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី២។ បច្ចុប្បន្ន ផែនការសកម្មភាពលើកទី២ បាននិងកំពុងរៀបចំ និងស្នើការអនុម័តពីគណៈរដ្ឋមន្ត្រី។ ក្រុមការងារនេះមានតួនាទីក្នុងការបង្កើតអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីស្តីពីការទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី។

- ក្រុមការងារស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ស្ថិតនៅក្រោមក្រុមការងារបច្ចេកទេសយេនឌ័រ ដែលមានគោលបំណងស្វែងរកការគាំទ្រ និងសម្របសម្រួលក្នុងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ បច្ចុប្បន្ននេះ ក្រុមការងារកំពុងសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធក្នុងការអនុវត្តន៍ក្របខ័ណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានិងកម្មវិធីពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច។

ក្រសួងកិច្ចការនារីក៏មានតំណាងនៅក្នុងក្រុមការងាររបច្ចេកទេសចម្រុះ នៃវិស័យផ្សេងៗទៀតដូចជា ក្រុមការងាររៀបចំផែនការ និងកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សុខភាពការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ សន្តិសុខស្បៀងភាពជាដៃគូ និងសុខដុមនីយកម្ម វិមជ្ឈការ និងវិសហមជ្ឈការ និងអប់រំជាដើម។

### *អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ឆ្ពោះទៅរកសមភាពយេនឌ័រ (Program Based Approach-PBA)*

អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី មានគោលដៅដើម្បីលើកកម្ពស់ភាពជាម្ចាស់ ធានានូវប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន ការពង្រឹងសមត្ថភាព និងប្រព័ន្ធការងារជាតិ រួមទាំងការធ្វើផែនការថវិកា លទ្ធកម្ម របាយការណ៍ គណនេយ្យភាព សវនកម្ម ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ក៏បានអនុវត្តនៅក្នុងកម្មវិធីអភិវឌ្ឍក្នុងវិស័យមួយចំនួនរបស់រាជរដ្ឋាភិបាលដូចជា វិស័យសុខភាព អប់រំ វិមជ្ឈការនិងវិសហមជ្ឈការ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បរិស្ថាន ពាណិជ្ជកម្ម មេរោគអេដស៍/ជំងឺអេដស៍ និងការកសាងផែនការ ព្រមទាំងកម្មវិធីកាត់បន្ថយភាពក្រីក្រជាដើម។ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីឆ្ពោះទៅរកសមភាពយេនឌ័រ កំពុងស្ថិតក្នុងការរៀបចំ ដែលដឹកនាំ និងសម្របសម្រួលដោយក្រសួងកិច្ចការនារី ដែលកំពុងចាប់ផ្តើមលើវិស័យពីរ គឺៈ

១. ការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ

២. ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។

## *ក្រុមការងារបញ្ជ្រាបយេនឌ័រតាមក្រសួង ស្ថាប័ន*

ក្រុមការងារនេះបានបង្កើតឡើងតាំងពីឆ្នាំ២០០៥នៅគ្រប់ក្រសួង ស្ថាប័នដែលដឹកនាំដោយរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ អគ្គនាយក ឬអគ្គនាយករង ព្រមទាំងមានសមាជិកមកពីនាយកដ្ឋាននានាចំណុះឱ្យក្រសួង ស្ថាប័ននីមួយៗ និងមានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- ពិនិត្យ និងវិភាគទស្សនៈយេនឌ័រគ្រប់គោលនយោបាយ ផែនការ និងកម្មវិធីរបស់វិស័យនីមួយៗ ។
- ស្វែងរកការគាំទ្រមតិនិងផ្ដល់នូវអនុសាសន៍ជូនថ្នាក់ដឹកនាំស្ដីពីបញ្ហាយេនឌ័រនៅក្នុងគ្រប់កម្មវិធី របស់ក្រសួង ស្ថាប័ន ។
- វិភាគស្ថានភាពស្ត្រីបច្ចុប្បន្នតាមក្រសួង ស្ថាប័ន និងផ្ដល់អនុសាសន៍ដើម្បីលើកកម្ពស់តួនាទីស្ត្រីនៅក្នុងមុខតំណែងធ្វើសេចក្ដីសម្រេច ។
- រៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ ។
- ចូលរួមនៅក្នុងដំណើរការកសាងកម្មវិធី និងដំណើរការធ្វើផែនការរបស់ក្រសួងដើម្បីធានាថាផែនការទាំងនោះឆ្លើយតបនឹងយេនឌ័រ ។
- ការអភិវឌ្ឍន៍សមត្ថភាពលើការងារបញ្ជ្រាបយេនឌ័រនិងការស្វែងរកការគាំទ្រមតិដើម្បីធានាថា ផែនការសកម្មភាព និងកម្មវិធីទាំងនោះឆ្លើយតបយេនឌ័រ ។
- កៀរគរធនធានសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ។

តាមរយៈយន្តការបញ្ជ្រាបយេនឌ័រតាមក្រសួងស្ថាប័ននេះមានក្រសួងស្ថាប័នចំនួន២៤បានបង្កើន និងកំពុងអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបេយនឌ័រតាមវិស័យ និងមានក្រសួងចំនួន២៣ដែលទទួលថវិការដ្ឋ ក្នុងអនុវត្តពាក់ព័ន្ធនឹងការអភិវឌ្ឍន៍សមត្ថភាព និងការរៀបចំព្រឹត្តិការណ៍យេនឌ័រសំខាន់ៗក្នុងក្រសួង ស្ថាប័នរបស់ខ្លួន។ នៅថ្នាក់ក្រោមជាតិ មានក្រសួងស្ថាប័នមួយចំនួន បានរៀបចំក្រុមការងារយេនឌ័រនៅតាមមន្ទីររបស់ខ្លួននៅថ្នាក់ខេត្ត និងរាជធានី ព្រមទាំងផ្ដល់ការបណ្ដុះបណ្ដាលបង្កើនចំណេះដឹងយេនឌ័រមួយចំនួន ។

## *សង្គមស៊ីវិល*

ព្រះរាជាណាចក្រកម្ពុជា មានអង្គការសង្គមស៊ីវិលជាច្រើនដែលបំពេញការងារក្នុងការលើកកម្ពស់សមភាពយេនឌ័រ ក្នុងនោះមានអង្គការសង្គមស៊ីវិលចំនួន១៥ ជាសមាជិកក្រុមការងារបច្ចេកទេសយេនឌ័រ[2]។ អង្គការសង្គមស៊ីវិលសំខាន់ៗមួយចំនួនដែលជាសមាជិកសកម្មនៃក្រុមការងារបច្ចេកទេសយេនឌ័ររួមមាន៖

- គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ គឺជាសម្ព័ន្ធអង្គការក្នុងស្រុកចំនួន៧២ ដែលធ្វើការដើម្បីលើកកម្ពស់ស្ថានភាពស្ត្រីនៅកម្ពុជា។ គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ផ្ដោតទៅលើការអនុវត្តន៍អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅកម្ពុជា។ ការងារទាំងនោះរួមមានការសិក្សាស្រាវជ្រាវ ការស្វែងរកការគាំទ្រមតិ បង្កើនការយល់ដឹង ការអភិវឌ្ឍន៍សមត្ថភាព និងការចែករំលែកព័ត៌មានរវាងសមាជិករបស់ខ្លួន។

- អង្គការយេនឌ័រ និងការអភិវឌ្ឍន៍នៅកម្ពុជា (GADC) ធ្វើការស្វែងរកការគាំទ្រមតិក្នុងការបញ្ជ្រាបយេនឌ័រក្នុងការបង្កើតគោលនយោបាយច្បាប់ កម្មវិធី និងគម្រោងនានា។ នៅថ្នាក់ឃុំ GADC ធ្វើការងារក្នុងផ្ដល់ភាពអង់អាចដល់ស្ត្រីតាមរយៈកម្មវិធីនៅសហគមន៍។

- គណៈកម្មាធិការលើកកម្ពស់ស្ត្រីក្នុងវិស័យនយោបាយ គឺជាបណ្ដាញការងារអង្គការមិនមែនរដ្ឋាភិបាលចំនួន៨ ដែលមានគោលបំណងដើម្បីបង្កើនការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចក្នុងវិស័យនយោបាយនៅគ្រប់កម្រិត។ បច្ចុប្បន្នគណៈកម្មាធិការនេះសម្របសម្រួលដោយអង្គការសីលការ ជាលេខាធិការដ្ឋាន។ ចំណុចគន្លឹះនៃយុទ្ធសាស្ត្ររបស់គណៈកម្មាធិការលើកកម្ពស់ស្ត្រីក្នុងវិស័យនយោបាយ បានបញ្ចូលនូវប្រព័ន្ធ បណ្ដាញការងារដ៏សំខាន់ និងមានប្រសិទ្ធភាពសម្រាប់ការអភិវឌ្ឍន៍សមត្ថភាព គោលនយោបាយឆ្លើយតបនឹងយេនឌ័រ និងការលើកទឹកចិត្តស្ត្រីជាអ្នកដឹកនាំវ័យក្មេង។

---

[2] បញ្ជីរាយនាមសមាជិកក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G) ឆ្នាំ២០១៤ របស់លេខាធិការដ្ឋាន TWG-G ក្រសួងកិច្ចការនារី

## ការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល

ក្រសួងកិច្ចការនារី បានធ្វើការងារបញ្ជ្រាបយេនឌ័រយ៉ាងសកម្មទៅក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។ល។

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)**

ក្នុងឆ្នាំ២០០៩គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)បានបង្កើតឡើងដើម្បីត្រួតពិនិត្យការអនុវត្តន៍កំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ នៅឆ្នាំ២០១០ គ.ជ.អ.ប បានបង្កើតកម្មវិធីជាតិ១០ឆ្នាំសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១០-២០១៩។ កម្មវិធីជាតិនេះផ្តល់ទិសដៅសម្រាប់ការអនុវត្តន៍របៀបវារៈកំណែទម្រង់ សម្រាប់១០ឆ្នាំបន្ទាប់។ កម្មវិធីជាតិ១០ឆ្នាំបានរៀបចំជាផែនការអនុវត្តន៍បីឆ្នាំដំបូងដែលហៅកាត់ថា "ផអ៣" ។ ផអ៣ មានអនុកម្មវិធីប្រាំមួយ ដែលមានក្រសួង ស្ថាប័នចំនួនប្រាំពីរអនុវត្តអនុកម្មវិធីទាំងនោះ ដែលមានក្រសួងកិច្ចការនារីដើរតួនាទីជាអ្នកសម្របសម្រួល និងគាំទ្រការបញ្ជ្រាបយេនឌ័រនៅក្នុងផអ៣។

យេនឌ័របានបញ្ជ្រាបទាំងនៅក្នុងកម្មវិធីជាតិ១០ឆ្នាំ និងផអ៣។ កម្មវិធីជាតិ១០ឆ្នាំ[3] និងផអ៣[4]បានផ្តោតការយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួម និងការទទួលបាន សិទ្ធិស្មើគ្នាសម្រាប់ស្ត្រីនិងបុរសដើម្បីទទួលបានមុខតំណែងជាអ្នកដឹកនាំ និងការធ្វើសេចក្តីសម្រេចផ្នែកនយោបាយ ធនធាននិងសេវាកម្ម។ នៅខែកុម្ភៈឆ្នាំ២០១៤ គ.ជ.អ.ប បានធ្វើសវនកម្មយេនឌ័រដែលបានត្រួតពិនិត្យឡើងវិញលើ ស្ថាប័នគោលនយោបាយសំខាន់ៗនិងសមិទ្ធផល ព្រមទាំងឧបសគ្គនានាក្នុងការបញ្ជ្រាបយេនឌ័រ។ សវនកម្មនេះបាន

3 ផែនការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩) របស់រាជរដ្ឋាភិបាលកម្ពុជា

4 ផែនការអនុវត្តន៍បីឆ្នាំដំបូង (២០១១-២០១៣) នៃផែនការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ផ្តល់ព័ត៌មានជាមូលដ្ឋានមួយសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងផអ៣បន្ទាប់។គ.ជ.អ.ប កំពុងសាកល្បងអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គមដើម្បីពង្រឹងអភិបាលកិច្ចល្អក្នុង វិស័យចំនួន៣៖ វិស័យអប់រំ វិស័យសុខាភិបាល និងការគ្រប់គ្រងដឹកនាំរបស់ក្រុមប្រឹក្សាឃុំសង្កាត់។ការអនុវត្តន៍នេះនឹងផ្តល់ឱកាសជាយុទ្ធសាស្ត្រសម្រាប់មន្ទីរនិងការិយាល័យកិច្ចការនារីនៅថ្នាក់ក្រោមជាតិ ដើម្បីបង្កើនការផ្តល់សេវា និងការចូលរួមរបស់ស្ត្រីក្នុងការឆ្លើយតបនឹងសមភាពយេនឌ័រ។

**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងផែនការថវិកាឆ្លើយតបនឹងយេនឌ័រ៖** កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២ បង្កើតឡើងក្នុងឆ្នាំ២០០៨ ដោយមានចក្ខុវិស័យរយៈពេលវែងដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានលក្ខណៈបទដ្ឋានអន្តរជាតិមួយនៅត្រឹមឆ្នាំ២០១៥។ យេនឌ័របានដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពរួមទី២ (CAP2)៖ «ការអភិវឌ្ឍន៍គោលនយោបាយស្តីពីសមាហរណកម្មថវិកាដើម្បីបន្តធ្វើឱ្យប្រសើរឡើងនូវការធ្វើសមាហរណកម្មនៃថវិកាចរន្ត និងថវិកាមូលធនតាមរយៈការផ្តួចផ្តើមជាបន្តបន្ទាប់ដូចជាក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) ផែនការយុទ្ធសាស្ត្រថវិកា (BSP) និងថវិកាតាមកម្មវិធី(PB) ។ គោលបំណង៣២.១ ក៏បានបញ្ចូលការកាត់បន្ថយភាពក្រីក្រនិងសេចក្តីថ្លែងការណ៍យេនឌ័រដែលទាក់ទងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី»[5]។ បច្ចុប្បន្ន មានក្រសួងចំនួនប្រាំពីរបាន និងកំពុងអនុវត្តថវិកាតាមកម្មវិធីដែលនឹងបង្កើនដល់១០ក្រសួងនៅឆ្នាំ២០១៥។ ការប្រើប្រាស់ថវិកាតាមកម្មវិធីជាលក្ខខ័ណ្ឌចាំបាច់ដើម្បីអនុវត្តផែនការថវិកាឆ្លើយតបនឹងយេនឌ័រ ។

ក្រសួងកិច្ចការនារី បានបង្កើតឱ្យមានឧបករណ៍ និងវិធីសាស្ត្រនៃការរៀបចំផែនការថវិកាដែលឆ្លើយតបនឹងយេនឌ័រដល់ក្រសួងស្ថាប័នពាក់ព័ន្ធសម្រាប់អនុវត្តការប្រើប្រាស់ថវិកាតាមកម្មវិធី។ គោលដៅយេនឌ័រជាក់លាក់បានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិកាក្រសួងចំនួនបី គឺក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់[6]។ ផែនការថវិកាដែលឆ្លើយតបនឹងយេនឌ័រក៏ត្រូវបានដាក់បញ្ចូលផងដែរទៅក្នុងអនុកម្មវិធីទី៤នៃផអ៣របស់កម្មវិធីជាតិ១០ឆ្នាំ

[5] កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២ (ឆ្នាំ២០០៨) ទំព័រទី៩

[6] របាយការណ៍ប្រចាំឆ្នាំ២០១៣ របស់គម្រោងភាពជាដៃគូដើម្បីសមធម៌យេនឌ័រ ក្រសួងកិច្ចការនារី

សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ** មានគោលដៅប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់សេវាដ៏ស័ក្តិសិទ្ធិ តាមរយៈការធ្វើឱ្យរដ្ឋបាលសាធារណៈកាន់តែមានតម្លាភាព ភាពឆ្លើយតប ប្រសិទ្ធភាព និងការលើកកម្ពស់ធន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈនិងផ្តោតលើសេវាសាធារណៈ។ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១០-២០១៣ មានគោលបំណងដើម្បីធ្វើ ឱ្យរដ្ឋបាលសាធារណៈផ្តល់សេវាប្រកបដោយប្រសិទ្ធភាពបន្ថែមទៀតដោយផ្តោតលើវិស័យជាយុទ្ធសាស្ត្រចំនួនបី៖

១. ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ
២. ការអភិវឌ្ឍន៍សមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស
៣. កំណែទម្រង់ប្រាក់បៀវត្សរ៍ និងប្រព័ន្ធលើកទឹកចិត្ត។

ភាពជោគជ័យរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សមភាពយេនឌ័រ ក្នុងកម្មវិធីនេះគឺជាការដាក់ចេញនូវសេចក្តីណែនាំរបស់ក្រសួងមុខងារសាធារណៈ ស្តីពីការជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌថ្មី ដោយកំណត់កម្រិតចំនួន ពី២០%-៥០%សម្រាប់ស្ត្រី[7]។ ជាលទ្ធផលចំនួនមន្ត្រីរាជការនារីបានកើនឡើងពី៣២% នៅក្នុងឆ្នាំ២០០៧[8] ដល់ ៣៧% នៅឆ្នាំ២០១៣[9]។ លើសពីនេះទៀតរាជរដ្ឋាភិបាលកម្ពុជាបានចេញព្រះរាជក្រឹត្យស្តីពីការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិលជាស្ត្រី។

## បញ្ហាប្រឈម

- ដោយកម្រិតនៃការប្តេជ្ញាចិត្ត និងការយកចិត្តទុកដាក់លើបញ្ហាយេនឌ័រកាន់តែមានភាពប្រសើរឡើង តម្រូវឱ្យមានការពង្រឹងសមត្ថភាព និងជំនាញជាក់ស្តែងរបស់ក្រសួង ស្ថាប័ន ក្នុងការវិភាគ ការស្វែងរកការគាំទ្រមតិ និងការបញ្ជ្រាបយេនឌ័រឱ្យបានស៊ីជម្រៅ ។
- ស្របពេលដែលវឌ្ឍនភាពនៃការបញ្ចូលយេនឌ័រនៅក្នុងច្បាប់ គោលនយោបាយ ផែនការ និងកម្មវិធីនានាតាមវិស័យកំពុងដំណើរការល្អ ការអនុវត្តន៍ជាក់ស្តែង

7 ផែនការក្របខ័ណ្ឌក្រសួងស្ថាប័នប្រចាំឆ្នាំ២០០៨ របស់ក្រសួងមុខងារសាធារណៈ
8 បញ្ជីស្ថិតិមន្ត្រីរាជការស៊ីវិលឆ្នាំ២០០៨ របស់ក្រសួងមុខងារសាធារណៈ
9 បញ្ជីស្ថិតិមន្ត្រីរាជការស៊ីវិលឆ្នាំ២០១៤ របស់ក្រសួងមុខងារសាធារណៈ

នៃច្បាប់គោលនយោបាយ ផែនការ និងកម្មវិធីទាំងនេះនៅមានគម្លាតនៅឡើយ។

- មានគម្រោង និងកម្មវិធីជាច្រើនបាន និងកំពុងយកចិត្តទុកដាក់ និងបញ្ជាក់អំពីការគាំទ្ររបស់ខ្លួន លើការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ប៉ុន្តែសកម្មភាព និងកម្មវិធីទាំងនោះ ពុំទាន់បានប្រមូលផ្តុំជាលក្ខណៈអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីនៅឡើយ ជាពិសេសលទ្ធភាពរបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធក្នុងការសម្របសម្រួលនៅមានកម្រិត។
- ការសម្របសម្រួលសកម្មភាពបញ្ជ្រាបយេនឌ័រនៅមានកម្រិត
- ទំនាក់ទំនងរវាងនាយកដ្ឋានជំនាញរបស់ក្រសួងកិច្ចការនារី ជាមួយក្រុមការងារបញ្ជ្រាបយេនឌ័រនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងជាមួយក្រុមការងារបច្ចេកទេសផ្សេងៗទៀតនៅមានកម្រិត។
- ថវិកាសម្រាប់អនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅមានកម្រិត។
- ផ្នត់គំនិតរបស់ថ្នាក់ដឹកនាំក្រសួង បុគ្គល និងសង្គមមួយចំនួននៅតែបន្តយល់ថាការងារបញ្ជ្រាបយេនឌ័រ គឺជាបន្ទុករបស់ក្រសួងកិច្ចការនារី ។
- យុទ្ធសាស្ត្រក្នុងការបញ្ជ្រាបយេនឌ័រតាមក្រសួង ស្ថាប័នពុំសូវមានការត្រួតពិនិត្យតាមដាន វាយតម្លៃ ទៅតាមតម្រូវការជាក់ស្តែង។
- តម្រូវឱ្យមានការបន្តគាំទ្របន្ថែមទៀត ក្នុងការអនុវត្តន៍មុខងាររបស់យន្តការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាពនៅមានកម្រិត ជាពិសេសគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការកិច្ចការនារីនិងកុមារថ្នាក់ ឃុំ សង្កាត់ និងបណ្តាញយេនឌ័រតាមមន្ទីរវិស័យ ។

## អនុសាសន៍សម្រាប់គោលនយោបាយ

ការអភិវឌ្ឍន៍សមត្ថភាពគឺជាតម្រូវការចាំបាច់ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗនៅក្នុងស្ថាប័ន និងសមត្ថភាពសម្រាប់ការអនុវត្តកម្មវិធី និងគោលនយោបាយដែលឆ្លើយតបនឹងយេនឌ័រ។ ក្នុងពេលដែលក្រសួងកិច្ចការនារីរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់រយៈពេល៥ឆ្នាំខាងមុខ មានបញ្ហាប្រឈមមុខមួយចំនួនដែលទាមទារឱ្យមានការអភិវឌ្ឍន៍សមត្ថភាពទូលំទូលាយ។ ខាងក្រោមនេះគឺជាអនុសាសន៍ឆ្ពោះទៅសម្រេចគោលបំណងនេះ៖

| | |
|---|---|
| • អភិវឌ្ឍសមត្ថភាពរបស់ក្រសួងកិច្ចការនារីលើការវិភាគយេនឌ័រក្នុងគោលនយោបាយដែលឆ្លើយតបនឹងយេនឌ័រ ការស្វែងរកការគាំទ្រមតិការសម្របសម្រួលដើម្បីពង្រឹងលទ្ធភាពក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលនៅគ្រប់កម្រិត។ | កកន |
| • ពង្រឹងសមត្ថភាពក្នុងការវិភាគ និងការធ្វើផែនការសម្រាប់បញ្ជ្រាបយេនឌ័រនៅក្នុងក្រសួង ស្ថាប័ន រួមទាំងការប្រមូល និងវិភាគទិន្នន័យរបស់ក្រសួងផែនការ និងនៅតាមក្រសួងស្ថាប័ននានា ព្រមទាំងពង្រឹងសមត្ថភាពនៃការប្រមូលទិន្នន័យផ្ទៃក្នុងរបស់ក្រសួងកិច្ចការនារី។ | GMAGs<br>កកន<br>ក្រសួងផែនការ |
| • ពង្រឹងទំនាក់ទំនងឱ្យកាន់តែរឹងមាំបន្ថែមទៀតរវាងនាយកដ្ឋានបច្ចេកទេសក្រសួងកិច្ចការនារីនិងក្រុមការងារយេនឌ័រតាមក្រសួងស្ថាប័ន (GMAGs) ព្រមទាំងជាមួយក្រុមការងារបច្ចេកទេសចម្រុះផ្សេងៗ (TWGs) ហើយធានាថា ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមក្រសួងស្ថាប័ន (GMAPs) បានកែសម្រួលដោយផ្អែកលើរបកគំហើញ និងអនុសាសន៍របស់ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ និងបានដាក់បញ្ចូលយ៉ាងពេញលេញទៅក្នុងផែនការមេ និងវដ្តនៃផែនការថវិការបស់ក្រសួង ស្ថាប័ន ព្រមទាំងពង្រឹងការប្រព័ន្ធត្រួតពិនិត្យតាមដាន វាយតម្លៃ និងការធ្វើរបាយការណ៍មកក្រសួងកិច្ចការនារី។ | កកន<br>GMAGs<br>TWG-G<br>TWGs |

| | |
|---|---|
| • ក្រសួងកិច្ចការនារីគួរប្រើប្រាស់បណ្ដាញថ្នាក់ក្រោមជាតិរបស់ខ្លួន ឱ្យបានកាន់តែប្រសើរឡើងក្នុងការលើកកម្ពស់គណនេយ្យភាពសង្គមដែលឆ្លើយតបនឹងយេនឌ័រនៅថ្នាក់មូលដ្ឋាន ជាពិសេស តាមរយៈការពង្រឹងទំនាក់ទំនងជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងអនុកម្មវិធីទាំងប្រាំមួយនៃផអ៣ ក្នុងក្របខ័ណ្ឌគណនេយ្យភាពសង្គម និងអភិបាលកិច្ចល្អ (ក្រុមប្រឹក្សាឃុំ សង្កាត់) និងការផ្ដល់សេវា (ការអប់រំ សុខភាព និងសេវាផ្លូវច្បាប់) និងកិច្ចគាំពារសង្គម។ | កកន<br>លេខាធិការដ្ឋាន<br>គ.ជ.អ.ប<br>ក្រសួងមហាផ្ទៃ |
| • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គួរបន្តអនុវត្តការផ្ដួចផ្ដើមក្នុងការរៀបចំផែនការថវិកាដែលឆ្លើយតបទៅនឹងយេនឌ័រ (GRB) ក្នុង ក្របខ័ណ្ឌកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) និងក្របខ័ណ្ឌរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត ដូចជា ការដាក់បញ្ចូលប្រយោគយេនឌ័រទៅក្នុងគោលការណ៍ណែនាំសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP) និងថវិកាតាមកម្មវិធីសម្រាប់ក្រសួង ស្ថាប័ន និងពន្លឿនការរៀបចំគោលនយោបាយ រៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រនៅថ្នាក់ក្រោមជាតិ ដើម្បីធានាថា យេនឌ័រត្រូវបានយកចិត្តទុកដាក់ និងដាក់បញ្ចូលក្នុងដំណើរការនៃការរៀបចំថវិកា ជាពិសេសក្នុងសូចនាករគោលដៅប្រចាំឆ្នាំ និងលទ្ធផលចុងក្រោយ។ | ក្រសួងសេដ្ឋកិច្ច<br>និងហិរញ្ញវត្ថុ<br>កកន<br>លេខាធិការដ្ឋាន<br>គ.ជ.អ.ប |
| • ក្រសួង ស្ថាប័នពាក់ព័ន្ធ គួរពង្រីកប្រសិទ្ធភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យរបស់ខ្លួន តាមរយៈការបន្តបញ្ចូលឱ្យបានពេញលេញ ក្នុងផែនការមេរបស់ខ្លួន និងកៀរគរធនធានពីដៃគូពាក់ព័ន្ធ និងថវិការដ្ឋសម្រាប់ការអនុវត្តន៍ ។ | |
| • ក្រសួងកិច្ចការនារី គួរបញ្ចូលនូវអនុសាសន៍ជាក់លាក់សម្រាប់បញ្ជ្រាបយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ (NSPS) និងឧបករណ៍គាំពារសង្គមនានា ក្នុងដំណើរការកែសម្រួលផែនការនេះ។ | កកន |

| | |
|---|---|
| • ក្រសួងកិច្ចការនារីគួរប្រើប្រាស់បទពិសោធន៍របស់អង្គការពលកម្មអន្តរជាតិ (ILO) និងគ.ជ.អ.ប ក្នុងលើកទឹកចិត្តដល់ក្រុមការងារយេនឌ័ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសវនកម្មយេនឌ័រសម្រាប់ការវាយតម្លៃការបញ្ជ្រាបយេនឌ័ររបស់ក្រសួង ស្ថាប័ននៅតាមវិស័យ និងកម្មវិធីកំណែទម្រង់នានា។ | កកន<br>GMAGs |
| • បំប៉នសមត្ថភាព និងចំណេះដឹងរបស់មន្ត្រីគ្រប់ជាន់ថ្នាក់ក្នុងការបញ្ជ្រាបយេនឌ័រ និងធ្វើការតាមដានការអនុវត្តដែលពាក់ព័ន្ធនឹងយេនឌ័រ។ | TWG-G |
| • ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ គួរពិចារណាក្នុងការពង្រីកលទ្ធភាព និងកិច្ចការ របស់ខ្លួន ដើម្បីជំរុញ និងអនុវត្តការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ ជាពិសេសនៅតាមមន្ទីរវិស័យរបស់ខ្លួន ដូចជាការពង្រឹងសមត្ថភាព ការរៀបចំក្រុមការងារយេនឌ័រនៅតាមមន្ទីររបស់ខ្លួន ជាដើម ។ | |

# សេចក្តីថ្លែងអំណរគុណ

ការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាត្រូវបានចងក្រងឡើងនៅក្រោមការដឹកនាំ និងសម្របសម្រួលដោយក្រសួងកិច្ចការនារី ដោយមានការគាំទ្រនិងរួមចំណែកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។ ក្រសួងកិច្ចការនារីសូមថ្លែងអំណរគុណ ជូនចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី ដែលបានចូលរួមចំណែកក្នុងការរៀបចំ ឯកសារនេះ ដូចតទៅ៖

**ក្រុមការងាររៀបចំការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា** ទទួលខុសត្រូវលើដំណើរការរៀប ចំឯកសារទាំងមូល ក្រោមការដឹកនាំរបស់ លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។ ក្រុមការងារមានលោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការ ជាប្រធាន និងគាំទ្របច្ចេកទេសដោយផ្ទាល់ពីលោកជំទាវ កេត សំអាត ទីប្រឹក្សាជាន់ខ្ពស់ ក្រសួងកិច្ចការនារី លោកជំទាវ គឹម ស៊ីផាត់ អគ្គនាយិកា ក្រសួងកិច្ចការនារី និង លោក ថេ ឈុនហាក់អគ្គនាយករងក្រសួងកិច្ចការនារីលោកស្រី ញាណ សុចិត្រា ប្រធាននាយកដ្ឋាន សមភាពយេនឌ័រ លោកស្រី តែ រួចលីម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ និងសមាជិក ផ្សេងៗទៀតមកពីនាយកដ្ឋានបច្ចេកទេសនានាចំណុះក្រសួងកិច្ចការនារី។ ក្រុមការងារមាន ការគាំទ្រផ្នែកបច្ចេកទេសពីគម្រោង **ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ** (PGEIII) ដែលមាន លោកស្រី Mia Hyun ជាទីប្រឹក្សាជាន់ខ្ពស់ប្រចាំក្រសួងកិច្ចការនារី ជាអ្នកសម្របសម្រួល ទូទៅ គាំទ្រដោយក្រុមអ្នកជំនាញតាមវិស័យរបស់គម្រោង រួមមាន លោកស្រី ឌី ម៉ានី លោក ប៉ែន បូរី លោកស្រី ហេង សិលទិ លោក ឈន ថាវរិទ្ធិ៍ និង លោក គឹម សុពណ៌។ **ក្រុមការងារបច្ចេកទេសយេនឌ័រ** (TWG-G) បានផ្តល់ជាវេទិកាដ៏សំខាន់ក្នុងការពិគ្រោះ យោបល់ជាមួយអ្នកពាក់ព័ន្ធ និងក្រុមអ្នកជួយកែសម្រួល (peer reviewers) ដែលជាអ្នក ជំនាញមកពីក្រសួងកិច្ចការនារី ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល បានជួយ ពិនិត្យ ឡើងវិញលើសេចក្តីព្រាងតាមជំនាញពាក់ព័ន្ធ។ បច្ចេកទេសទាក់ទងនឹងរូបភាព ការរចនា និងសម្ភារៈសម្រាប់ផ្សព្វផ្សាយផ្តល់ដោយ Good Morning Beautiful ។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី១៖** ជំពូកនេះដឹកនាំរៀបចំដោយលោកជំទាវ ឃឹម ចំរើន លោក ថេ ឈុនហាក់ និង លោកស្រី ញាណ សុចិត្រា ដោយមានជំនួយបច្ចេកទេសក្នុង ការសិក្សាស្រាវជ្រាវនិងធ្វើបច្ចុប្បន្នភាពពីអ្នកជំនាញនៃគម្រោង PGE III រួមមាន៖ លោក ប៉ែន បូរី និង លោក ឈួន ថាវរិទ្ធិ៍ ក្រោមការគាំទ្រនិងផ្តល់យោបល់ពី លោកស្រី Mia Hyun និងជំនួយបច្ចេកទេសពីលោកស្រី Loksee Leung លោក គឹម សុពណ៌ និងលោកស្រី កង វីរីយ៉ា។

ក្រសួងកិច្ចការនារី
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣ សង្កាត់ស្ទឹងមានជ័យ
ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ហ្វាក់ : (+៨៥៥) ២៣ ៨៨០ ៧៣៧
អ៊ីម៉េល : mwa@online.com.kh
វេបសាយ : www.mowa.gov.kh
ហ្វេសប៊ុក : www.facebook.com/mowa.gov.kh